សមាគមឧកញ៉ាកម្ពុជា

# ព្រឹត្តិបត្រព័ត៌មានសមាគមឧកញ៉ាកម្ពុជា

## ឆ្នាំទី២ លេខ៦ ត្រីមាសទី២ ឆ្នាំ២០២៥




ផលិតដោយៈ អគ្គលេខាធិការដ្ឋាន
សមាគមឧកញ៉ាកម្ពុជា

# មាតិកា


- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយអ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីពិសាអាហារសាមគ្គីអបអរសាទរបុណ្យចូលឆ្នាំថ្មីជាមួយថ្នាក់ដឹកនាំ បុគ្គលិកកម្មករ និយោជកនៃក្រុមហ៊ុនកំពង់ស្ពឺ ស៊ូហ្គើរ........................................................................................១
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ចាត់តាំងឧកញ៉ាវេជ្ជបណ្ឌិត ជា សុខឃាង ជាតំណាងដើម្បីចូលរួម "ជំនួបធុរកិច្ចរវាងអ្នកទិញ និងអ្នកលក់ក្នុងវិស័យវាយនភណ្ឌ ឆ្នាំ២០២៥...........................................៣
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា ក.ផ.ផ លើកទី៥........................................................................................................
- អ្នកឧកញ៉ាបណ្ឌិត វិញ ហ៊្សួរ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងកម្មវិធីប្រកាសសម្ពោធដាក់ឱប្រើប្រាស់អនុវត្តជាផ្លូវការ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំង៤នៅភូមភាគឦសាន"..............................................៦
- អ្នកឧកញ៉ា លាង ម៉េង តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខជូនដល់ព្រះរាជាណាចក្រកម្ពុជា ..................................................................៨
- ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណរ័ត្ន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីដាក់សម្ពោធឱដំណើរការខ្សែច្រវាក់ផលិតកម្មថ្មី និងរោងចក្រតម្លើងគ្រឿងបង្គុំរថយន្ត Ford របស់ក្រុមហ៊ុន RMA CAMBODIA..........................................៩
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក( ក.ប.យ.អ. )...........................................................................................................១១
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ អមដំណើរដោយលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាច្រើនរូបបានចូលរួមគោរពវិញ្ញាណក្ខន្ធ មហាឧបាសក ឡាវ តេកសេង...................................................១៣
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដោយលោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាច្រើនរូបបានចូលរួមកម្មវិធីគោរពវិញ្ញាណក្ខន្ធ ឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ នាង ខេង.................................................១៤
- ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ប្រគល់ថវិកាជូនកាកបាទក្រហមកម្ពុជា ក្នុងឱកាសខួបទី១៦២ ទិវាកាកបាទក្រហម និង អឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៥ និងខួបលើកទី៧០ នៃកាកបាទក្រហមកម្ពុជា.....................១៥
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមពិធីសម្ពោធដាក់ឱដំណើជាផ្លូវការ «រោងចក្រផលិតស៊ីម៉ងត៍ របស់ក្រុមហ៊ុន ខនស៍ ខេធី ស៊ីមេន (ភ្នំពេញ)ឯ.ក»....................................................១៨
- **សម្តេចពញាចក្រ ហេង សំរិន** ប្រធានកិត្តយក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យលោកអ្នកឧកញ៉ា លី យ៉ុងផាត់ និងលោកជំទាវអញ្ជើញចូលសួរសុខទុក្ខ និងគោរពជូនពរ.......................២០
- គណៈប្រតិសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៦ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនៅប្រទេសម៉ាឡេស៊ី........................................................................................................ ២១

- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមអមដំណើរ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសជប៉ុន..........................................២២
- ថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ចូលរួមជំនួបពាណិជ្ជកម្មកម្ពុជា–កាណាដា...............................២៥
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំអ្នកឧកញ៉ា ឧកញ៉ា ជាច្រើនរូបចូលរួមពិធីបើកយុទ្ធនាការ «១ម៉ឺននាក ១ម៉ឺនរៀល»...........................................................................................២២
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ចាត់តាំងអ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការចូលរួមកម្មវិធីផ្លាស់ប្តូរសហគ្រិនវ័យក្មេងកម្ពុជា–ចិន ឆ្នាំ២០២៥ តាមសំណើរបស់ ផ្ទះយុវជន មិត្តភាពកម្ពុជា–ចិន........................២៧
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកអំណោយប្រគល់ជូនកងទ័ពដែលកំពុងឈរជើងនៅជួរមុខការពារព្រំដែនកម្ពុជា–ថៃ ទិសទី១ ខេត្តព្រះវិហារ..........................................៣០
- អ្នកឧកញ៉ា ទី គឹមស្រ៊ាន ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមគោរពវិញ្ញាណក្ខន្ធឧបាសក តាំង គឹមស្រេង ដែលត្រូវជាឪពុកក្មេង ឧកញ៉ា ឈិន សុង...........................................................................................៣២
- គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម "ជំនួបផ្គូផ្គងធុរកិច្ចឥណ្ឌា–កម្ពុជា" ដើម្បីកសាងទំនាក់ទំនងធុរកិច្ច និងស្វែងរកឱកាសចាប់ដៃគូវិនិយោគ...........................................................................................៣៣
- លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីអបអរសាទរការដំណើរការជាផ្លូវការ១ឆ្នាំ របស់សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា...........................................................................៣៤
- អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធការ ចូលរួម "កិច្ចប្រជុំស្តីពីការរៀបចំកម្មវិធីគាំទ្រថ្មីក្នុងការពង្រឹងបណ្តុំឧស្សាហកម្ម និងជំរុញការផ្សារភ្ជាប់ខ្សែច្រវាក់ផលិតកម្ម រវាងសហគ្រិនធុនតូច និងមធ្យម និងវិនិយោគិនក្នុងស្រុក និងបរទេស"............៣៥

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយ ថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា អញ្ជើញចូលរួមក្នុងពិធីពិសាអាហារសាមគ្គី អបអរសាទរឆ្នាំថ្មីជាមួយថ្នាក់ដឹកនាំបុគ្គលិកកម្មករនិយោជិត នៃក្រុមហ៊ុនកំពង់ស្ពឺ ស៊ូហ្គើរ









នាល្ងាចថ្ងៃអាទិត្យ ៩កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា រួមជាមួយ អ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារសាមគ្គីអបអរសាទរឆ្នាំថ្មីជាមួយថ្នាក់ដឹកនាំ បុគ្គលិក កម្មករនិយោជិត នៃក្រុមហ៊ុនកំពង់ស្ពឺ ស៊ូហ្គើរ ចំនួនប្រមាណ ៦ពាន់នាក់ ក្រោមអធិបតីភាព ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ស្ពឺ ដោយពិធីជួបជុំដ៏រីករាយនេះប្រព្រឹត្តទៅក្នុងបរិវេណផ្សារចម្ការអំពៅ ស្ថិតក្នុងឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។

អ្នកឧកញ៉ា សេង ញ៉ក់ ជំនួសមុខឱ្យក្រុមការងារក្រុមហ៊ុនកំពង់ស្ពឺ ស៊ូហ្គើរ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ដែលបានផ្តល់កិត្តិយសចំពោះក្រុមគ្រួសារ កំពង់ស្ពឺ ស៊ូហ្គើរ ដែលជានិច្ចជាកាល ឯកឧត្តមតែងតែអញ្ជើញមកចូលរួមជាមួយបងប្អូនដោយផ្ទាល់។ ជាមួយគ្នានោះ អ្នកឧកញ៉ា ក៏បានរាយការណ៍ពីសមិទ្ធផលសម្រេចបានរបស់ក្រុមហ៊ុនក្នុងរយៈកាលជាងមួយទសវត្សរ៍របស់ខ្លួន។

ថ្លែងទៅកាន់អង្គពិធី ជាមួយនឹងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះអ្វីដែលជាសមិទ្ធផលសម្រេចបានរបស់ក្រុមហ៊ុន ឯកឧត្តម ហ៊ុន ម៉ានី បានធ្វើការថ្លែងអំណរគុណដល់ក្រុមហ៊ុនកំពង់ស្ពឺ ស៊ូហ្គើរ ដែលបានជ្រើសរើសខេត្តកំពង់ស្ពឺ និងនិយាយដោយឡែក ជ្រើសរើសស្រុកថ្ពង និងស្រុកឱរ៉ាល់ធ្វើជាទីតាំងវិនិយោគជាចម្ការអំពៅ និងរោងចក្រផលិតស្ករសដ៏ធំមួយនៅក្នុងប្រទេសកម្ពុជាសម្រាប់នាំចេញដែលបាននាំមកនូវកិត្យានុភាពជាតិ ការបង្កើតការងារជូនប្រជាពលរដ្ឋ និងរួមចំណែកកសាងហេដ្ឋារចនាសម្ព័ន្ធនានានៅក្នុងមូលដ្ឋាន ក៏ដូចជាក្នុងវិស័យសង្គមកិច្ចតាមរយៈការផ្តល់នូវកញ្ចប់ថវិកាឧបត្ថម្ភសម្រាប់ស្ត្រីមានផ្ទៃពោះ និងបុគ្គលិកដែលទទួលមរណភាពជាដើម។

ឯកឧត្តមក៏បានគូសបញ្ជាក់អំពីប្រវត្តិសាស្ត្រតំបន់នេះដែលជាអតីតសមរភូមិក្នុងអតីតកាលដែលបានប្រែមុខមាត់មកជាតំបន់ដែលមានការអភិវឌ្ឍដោយសារសុខសន្តិភាព។ ឯកឧត្តមបានបន្តថា ក្រោមម្លប់នៃសន្តិភាព ពេលនេះ ម៉ោងនេះ គឺមានតែខ្មែរតែមួយស្ថិតក្រោមដំបូលរដ្ឋធម្មនុញ្ញតែមួយហើយយើងកំពុងរួបរួមគ្នាកសាងអភិវឌ្ឍជាតិបន្តទៅមុខ។

ក្នុងនោះ  ឯកឧត្តមក៏បានការថ្លែងអំណរគុណដល់មន្ត្រីរាជការក៏ដូចជាវិស័យឯកជនដែលបានចូលរួមគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលដែលបាននាំឱ្យការដាក់ចេញនូវកម្មវិធីនយោបាយទាំងឡាយទទួលបានលទ្ធផលផ្លែផ្កាជាបណ្តើរៗ។ ឯកឧត្តម សូមអំពាវនាវឱ្យបងប្អូនបន្តការជឿជាក់លើការដឹកនាំប្រកបដោយភាពឆ្លាតវៃ និងចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាដែលដឹកនាំដោយ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត។

សូមបញ្ជាក់ដែរថា  ក្នុងពិធីនេះក៏មានការចាប់ឆ្នោតផ្សងសំណាងជូនដល់បុគ្គលិកទាំងអស់របស់ក្រុមហ៊ុនផងដែរ  ដោយរួមមានរង្វាន់ដូចជា ម៉ូតូចំនួន ១០គ្រឿង, ទូរសព្ទចំនួន ៣០គ្រឿង និងកង្ហារចំនួន ១០០គ្រឿងផងដែរ។












# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ចាត់តាំង ឧកញ៉ាវេជ្ជបណ្ឌិត ជា សុខឃាង ជាតំណាងដើម្បីចូលរួមក្នុង «ជំនួបធុរកិច្ចរវាងអ្នកទិញ និងអ្នកលក់ក្នុងវិស័យវាយនភណ្ឌ ឆ្នាំ២០២៥»

នារសៀលថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៥ ដោយមានការចាត់តាំងពីលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ឧកញ៉ាវេជ្ជបណ្ឌិត ជា សុខឃាង និងសមាជិកសមាគមជាច្រើនរូប បានចូលរួមក្នុង “ជំនួបធុរកិច្ចរវាងអ្នកទិញនិងអ្នកលក់ក្នុងវិស័យវាយនភណ្ឌ ឆ្នាំ២០២៥” នៅសណ្ឋាគារ Fairfield by Marriot ក្រោមអធិបតីភាព ឯកឧត្តម ឱក ប៊ុង រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និង ឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានការចូលរួមពីតំណាងក្រសួង/ស្ថាប័នរដ្ឋ, សភាពាណិជ្ជកម្ម, សមាគម និងវិស័យឯកជនផងដែរ។

“ជំនួបធុរកិច្ចរវាងអ្នកទិញនិងអ្នកលក់ក្នុងវិស័យវាយនភណ្ឌ ឆ្នាំ២០២៥” ត្រូវបានរៀបចំឡើងដោយ សហព័ន្ធឧស្សាហកម្មឥណ្ឌារដ្ឋតាមិល ណាឌូ និងស្ថានទូតឥណ្ឌាប្រចាំកម្ពុជា ក្នុងគោលបំណងចែករំលែក និងផ្សព្វផ្សាយអំពីភាពរីកចម្រើននៃវិស័យវាយនភណ្ឌដែលជាវិស័យលេចធ្លោនិងអាទិភាព នៃរដ្ឋតាមិល ណាឌូ ជាពិសេសផលិតកម្មអំបោះ និងក្រណាត់ ក៏ដូចជាស្វែងយល់ និងស្វែងរកឱកាសចាប់ដៃគូវិនិយោគក្នុងវិស័យវាយនភណ្ឌជាមួយធុរជនកម្ពុជាផងដែរ។

សូមជម្រាបផងដែរថា ក្នុងដំណើរបេសកកម្មធុរកិច្ចនេះ សហព័ន្ធឧស្សាហកម្មឥណ្ឌារដ្ឋ តាមិល ណាឌូ បានដឹកនាំធុរជនឥណ្ឌា ១១ក្រុមហ៊ុន ដែលសុទ្ធសឹងជាអ្នកជួញដូរក្នុងវិស័យវាយនភណ្ឌប្រកបដោយសក្តានុពល។ សមាជិកសមាគមឧកញ៉ាកម្ពុជាក៏បានទស្សនាការដាក់តាំងបង្ហាញផលិតផលក្រណាត់ជាច្រើនប្រភេទនិងបានជួបផ្តួងធុរកិច្ច ផ្លាស់ប្តូរព័ត៌មាន ក៏ដូចជាភ្ជាប់ទំនាក់ទំនងជាមួយភាគីឥណ្ឌាគ្នាទៅវិញទៅមកសម្រាប់កិច្ចសហការធុរកិច្ចនាពេលអនាគតផងដែរ។




























CII - Government of Tamil Nadu
Textiles Buyer- Seller Meet &
Product Showcase

# អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.) លើកទី៥

ថ្ងៃអង្គារ ១១កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការនិងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជាបានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.) លើកទី៥ ក្រោមអធិបតីភាព ឯកឧត្តម ហួត ហាក់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធាន ក.ផ.ផ. ផងដែរ។

កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបន្តពិភាក្សា និងតាមដានវឌ្ឍនភាពការងារដែលបានដាក់ចេញដើម្បីពង្រឹងប្រសិទ្ធភាពអង្គភាពផ្ទៃក្នុងសំដៅសម្រេចឱ្យបានតាមផែនការយុទ្ធសាស្ត្រផ្សព្វផ្សាយទេសចរណ៍កម្ពុជាទៅកាន់ពិភពលោក និងទាក់ទាញភ្ញៀវទេសចរអន្តរជាតិមកកម្ពុជា។













# អ្នកឧកញ៉ាបណ្ឌិត វិញ ហ៊្សែ តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈ ប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីប្រកាសសម្ពោធដាក់ឱ្យអនុវត្តជាផ្លូវការ «កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន»









នាព្រឹកថ្ងៃពុធ ១២កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៥ អ្នកឧកញ៉ាបណ្ឌិតវិញ ហ៊្សែ អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីប្រកាសសម្ពោធដាក់ឱ្យអនុវត្តជាផ្លូវការ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួននៅភូមិភាគឦសាន" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនេះដែរ **សម្តេចធិបតី** បានមានប្រសាសន៍ថារាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់លើការអភិវឌ្ឍគ្រប់បណ្តាខេត្តទាំងអស់ជាពិសេសគឺកាត់បន្ថយគម្លាតការអភិវឌ្ឍខេត្តនៅភូមិភាគឦសាន ខណៈដែលខេត្តទាំងបួនគឺ ខេត្តក្រចេះ ស្ទឹងត្រែង ខេត្តមណ្ឌលគីរី និងខេត្តរតនគីរី មានកត្តាអំណោយផលដល់វិស័យកសិកម្ម កសិ-ឧស្សាហកម្ម និងទេសចរណ៍ ហើយរាជរដ្ឋាភិបាលបានផ្តល់ការលើកទឹកចិត្តលើសពីច្បាប់វិនិយោគដោយបើកវិសាលភាពធំទូលាយលើសពីគម្រោងវិនិយោគមានលក្ខណៈគ្រប់គ្រាន់ ( គ.ល.គ. ) ក្នុងវិស័យអាទិភាពដោយរួមបញ្ចូលទាំងវិស័យទូទៅ និងគម្រោងពង្រីកនៃ គ.ល.គ. ផងដែរ។ លើសពីនេះទៀត សម្រាប់សកម្មភាពធុរកិច្ចដែលកំពុងដំណើរការក្នុងខេត្តទាំងបួនតែមិនទាន់បានចុះបញ្ជីពន្ធដារ គឺអាចចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្តក្នុងឆ្នាំ២០២៥ ហើយទទួលបានការលើកលែងនូវពិន័យទោសទណ្ឌបំណុលពន្ធនិងការផាកពិន័យជាប្រាក់ចំពោះការមិនបានបំពេញអនុលោមភាពកន្លងមកផងដែរ។ ក្រោយពីបានចុះបញ្ជីពន្ធដាររួចរាល់សកម្មភាពធុរកិច្ចទាំងនេះក៏អាចស្នើសុំការលើកទឹកចិត្តដោយត្រូវចុះបញ្ជីជា គ.ល.គ. ក្នុងឆ្នាំ២០២៥ ។



**សម្តេចធិបតី** បានបន្ថែមថា **សម្តេច** ពិតជាចង់ឃើញថាកម្មវិធីពិសេសនេះជួយបង្កើត «ចរន្តសេដ្ឋកិច្ច» បានជាក់ស្តែងដល់ភូមិភាគព្រៀសានហើយជោគជ័យនេះអាចកើតឡើងបានទាល់តែមានការចូលរួមសហការពីភាគីពាក់ព័ន្ធទាំងអស់ទាំងផ្នែករដ្ឋ និងវិស័យឯកជន។ ទន្ទឹមនឹងនេះរាជរដ្ឋាភិបាលបានបង្កើតក្រុមការងារជំរុញ ការវិនិយោគក្នុងភូមិភាគព្រៀសាន (ក.វ.ព្រៀសាន) ដែលវិនិយោគិនអាចដាក់ពាក្យស្នើសុំការអនុម័តគម្រោង និងលិខិតស្នាមពាក់ព័ន្ធផ្សេងៗទៀត ជាមួយនឹងក្រុមការងារតែម្តងដោយពុំចាំបាច់ឆ្លងនីតិវិធីដោយឡែកៗតាមរយៈក្រសួង ស្ថាប័ននីមួយៗហើយនៅពេលដែលជួបបញ្ហាក៏អាចស្នើសុំការសម្របសម្រួលដោះស្រាយពីក្រុមការងារដោយផ្ទាល់តែម្តង ដែលមានការិយាល័យនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច (នៅ OCIC ជ្រោយចង្វារ) ឬនៅតាមរដ្ឋបាលខេត្តទាំងបួន។ ក្រុមការងារនេះជាច្រកចេញចូលតែ មួយដែលមានតួនាទីពិនិត្យវាយតម្លៃ និងផ្តល់ការអនុម័តគម្រោង, ផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនានា ជាកញ្ចប់ទៅលើគម្រោងវិនិយោគនៃកម្មវិធីពិសេស និងតាមដានត្រួតពិនិត្យលើការអនុវត្តគម្រោងទាំងនេះ។

**សម្តេច** បានបញ្ជាក់ថា កម្មវិធីពិសេសនេះផ្តោតលើការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម ដូច្នេះហើយរាជរដ្ឋាភិបាលបានបន្ធូរបន្ថយលក្ខខណ្ឌទំហំទុនវិនិយោគអប្បបរមាចាប់ពី ១០ម៉ឺនដុល្លារឡើងទៅគឺអាចស្នើសុំគោលការណ៍វិនិយោគពី ក.វ.ព្រៀសាន ដើម្បីចុះបញ្ជីជា គ.ល.គ. នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត តាមនីតិវិធីជាធរមាន។ ការដាក់ទំហំទុនបែបនេះគឺដើម្បីលើកទឹកចិត្តវិនិយោគិនក្នុងស្រុកឱ្យចូលរួមបានកាន់តែច្រើនតាមដែលអាចធ្វើទៅបាន។ មិនត្រឹមតែប៉ុណ្ណោះ រាជរដ្ឋាភិបាលបានត្រៀមថវិកាដើម្បីដាក់ចេញនូវកម្មវិធីហិរញ្ញប្បទានក្រោមអត្រាការប្រាក់សមរម្យ ដោយផ្តោតជាពិសេសលើសហគ្រាសធុនតូច និងមធ្យម, សហគមន៍កសិកម្មទំនើប និងសហគមន៍ទេសចរណ៍ តាមរយៈធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា (SME Bank)។ ចំពោះបញ្ហាកង្វះខាតធនធានមនុស្ស រាជរដ្ឋាភិបាលបានសម្រេចផ្តល់ការលើកទឹកចិត្ត ដោយកំណត់លក្ខខណ្ឌលើកលែងពន្ធលើប្រាក់បៀវត្សសម្រាប់កម្មករនិយោជិតជាជនជាតិខ្មែរដែលទទួលបានប្រាក់បៀវត្សប្រចាំខែស្មើនឹង ឬតិចជាង ២.០០០.០០០រៀល និងបម្រើការងារនៅក្នុង គ.ល.គ. ដែលមានប្រតិបត្តិការក្នុងខេត្តណាមួយនៃខេត្តទាំងបួននៅភូមិភាគព្រៀសាន។

សូមបញ្ជាក់ផងដែរថា ការអនុវត្តកម្មវិធីពិសេសនេះ គឺជាសក្ខីភាពនៃឆន្ទៈនយោបាយយ៉ាងមោះមុតរបស់រាជរដ្ឋាភិបាលនៅក្នុងកិច្ចខិតខំប្រឹងប្រែងការពារសន្តិភាព ស្ថិរភាព ឯករាជ្យភាព និងបូរណភាពទឹកដី ក៏ដូចជាការខិតខំពង្រីក និងចែកចាយផលលាភពីកំណើនសេដ្ឋកិច្ចទៅដល់គ្រប់មជ្ឈដ្ឋានប្រជាជនខ្មែរ។









# អ្នកឧកញ៉ា លាង ម៉េង តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ា ចូលរួមក្នុង ព្រះរាជពិធីបួងសួងចម្រើនសេចក្ដីសុខជូនដល់ព្រះរាជាណាចក្រកម្ពុជា









នាព្រឹកថ្ងៃចន្ទ ២រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៥ អ្នកឧកញ៉ា លាង ម៉េង អនុប្រធាន និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាចូលរួមក្នុងព្រះរាជពិធីបួង សួងចម្រើនសេចក្តីសុខជូនដល់ព្រះរាជាណាចក្រកម្ពុជានៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ក្រោមព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ព្រះករុណា ព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

សូមបញ្ជាក់ថា ការរៀបចំព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខដល់ព្រះរាជាណាចក្រកម្ពុជា គឺជាគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភាដើម្បីនាំមកនូវសេចក្តីសុខចម្រើន និងបញ្ចៀសអពមង្គលផ្សេងៗព្រមទាំងថ្វាយព្រះសព្ទសាធុការពរចំពោះ **ព្រះមហាក្សត្រ** និង **សម្តេចព្រះមហាក្សត្រី** មុននឹងឈានចូលដល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរដែលប្រព្រឹត្តទៅរយៈពេលបីថ្ងៃគឺចាប់ពីថ្ងៃទី១៤ រហូតដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៥។

ចំពោះការជ្រើសរើសមុខប្រាសាទអង្គរវត្តធ្វើជាទីតាំងសម្រាប់ប្រារព្ធព្រះរាជពិធីនេះគឺដោយសារតែទីតាំងដ៏ពិសិដ្ឋនេះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធរវាងកេរដំណែលប្រវត្តិសាស្ត្រនិងព្រលឹងបុព្វបុរសខ្មែរ ពោលគឺអង្គរវត្ត ជាទឹកដីដ៏ស័ក្តិសិទ្ធិនៃព្រលឹងបុព្វបុរសខ្មែរ និងជាទីតាំងដ៏រុងរឿងនៃប្រទេសខ្មែរកាលពីសម័យបុរាណ។ ដូច្នេះពិតជាអំណោយផលល្អសម្រាប់ការប្រារព្ធព្រះរាជពិធីនេះបួងសួងចម្រើនសេចក្តីសុខជូនដល់ព្រះរាជាណាចក្រកម្ពុជា។

## ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណរ័ត្ន តំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការខ្សែច្រវាក់ផលិតកម្មថ្មីនិងរោងចក្រដំឡើងគ្រឿងបង្គុំរថយន្ត Ford របស់ក្រុមហ៊ុន RMA CAMBODIA




ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២២ ខែមេសា ឆ្នាំ២០២៥ ឧកញ៉ាវេជ្ជបណ្ឌិត នង សុវណ្ណរ័ត្ន សមាជិកសកម្ម និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យដំណើរការខ្សែច្រវាក់ផលិតកម្មថ្មី និងរោងចក្រដំឡើងគ្រឿងបង្គុំរថយន្ត Ford របស់ក្រុមហ៊ុន RMA CAMBODIA ដែលស្ថិតនៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងឱកាសនេះដែរ **សម្តេចមហាបវរធិបតី** បានថ្លែងបង្ហាញមោទនភាព និងវាយតម្លៃខ្ពស់ចំពោះគ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យយានយន្តនៅកម្ពុជា ជាពិសេសចំពោះក្រុមហ៊ុនអន្តរជាតិ RMA Group ដែលជាក្រុមហ៊ុននាំមុខមួយក្នុងការផ្គត់ផ្គង់ផលិតផល និងសេវា ជូនដល់ប្រជាពលរដ្ឋកម្ពុជា និងក្រុមហ៊ុន Ford Motor Company ជាក្រុមហ៊ុនដ៏ធំរបស់អាម៉េរិកដែលបានផ្តល់ទំនុកចិត្តនិងជ្រើសរើសប្រទេសកម្ពុជាជាទីតាំងវិនិយោគរបស់ខ្លួនដើម្បីចែកចាយនៅលើទីផ្សារក្នុងស្រុកប្រកបដោយសក្តានុពលយោងទៅលើស្ថានភាពនៃការអភិវឌ្ឍរីកចម្រើន និងកំណើនជីវភាពជាបន្តបន្ទាប់របស់ប្រជាពលរដ្ឋកម្ពុជា។

**សម្តេចធិបតី** បានចាត់ទុកការវិវឌ្ឍន៍នេះស្តែងឱ្យឃើញពីស្ថានភាពដ៏ល្អប្រសើរលើវិស័យការងារ និងស្ថានភាពសង្គមកម្ពុជា ខណៈដែលកាលពីឆ្នាំ៩០ជាងកម្ពុជានាំចូលទាំងអស់តែបច្ចុប្បន្នមានផលិតផលជាច្រើនផលិតដោយកម្ពុជា ជាក់ស្តែងនៅលើតួម៉ាស៊ីនរបស់រថយន្ត Ford ត្រូវបានអនុញ្ញាត និងទទួលស្គាល់លើការវាយផ្លាកលេខថា ផលិតនៅកម្ពុជាផងដែរ។

**សម្តេចធិបតី** បានបន្ថែមថា កំណើនវិនិយោគនៅកម្ពុជាគឺដោយសារបរិយាកាសវិនិយោគមានភាពល្អប្រសើរហើយកែលម្អជាប់ជាប្រចាំជាពិសេសកម្ពុជារក្សាបានស្ថិរភាព ហើយរាល់ការវិនិយោគរបស់បរទេសផលប្រយោជន៍មុនគេ គឺការបង្កើតការងារ, ពលរដ្ឋមានលទ្ធភាពទិញរថយន្តថ្មីតម្លៃសមរម្យហើយជួយកាត់បន្ថយការនាំរថយន្តចាស់ចូលពីក្រៅប្រទេស។ ជាមួយគ្នានេះ **សម្តេចធិបតី** បានលើកទឹកចិត្តដល់ក្រុមហ៊ុនផលិត និងដំឡើងរថយន្តនៅក្នុងស្រុក ឱ្យផលិតរថយន្តក្នុងតម្លៃសមរម្យដើម្បីពលរដ្ឋមានលទ្ធភាពកាន់តែច្រើនក្នុងការទិញរថយន្តប្រើប្រាស់ និងមានភាពងាយស្រួលផ្លាស់ប្តូរគ្រឿងបន្លាស់ និងសេវាកម្មផងដែរ។











# អ្នកឧកញ៉ា ហ៊ិន ឡាក់ អគ្គលេខាធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិក (ក.ប.យ.អ.)












នាថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ិន ឡាក់ អគ្គលេខា ធិការ និងជាតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់ការអភិវឌ្ឍវិស័យយានយន្តនិងអេឡិចត្រូនិក (ក.ប.យ.អ.) នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រោមការដឹកនាំដោយឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា និងជាអនុប្រធានក.ប.យ.អ. តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តមស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាសហប្រធាន ក.ប.យ.អ. ផ្នែករាជរដ្ឋាភិបាល។

កិច្ចប្រជុំនេះ មានគោលបំណងសំខាន់ៗចំនួន ៤ រួមមាន៖ទី១-ពិភាក្សាលើលទ្ធផលគន្លឹះបឋមនៃរបាយការណ៍វាយតម្លៃវឌ្ឍនភាព ២ឆ្នាំ ក្នុងការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជា, ទី២-ពិភាក្សាលើស្ថានភាពបច្ចុប្បន្ន, បញ្ហាប្រឈម និងសំណូមពរក្នុងវិស័យទាំងពីរ ទី៣-កាលានុវត្តភាពក្នុងការអភិវឌ្ឍវិស័យទាំងពីរ និង ទី៤-កំណត់ទិសដៅការងារបន្ត។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមអគ្គលេខាធិការ សហប្រធានអង្គប្រជុំ បានសម្តែងសេចក្តីសោមនស្សរីករាយ និងស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ, គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងវិស័យឯកជនដែលបានអញ្ជើញចូលរួមកិច្ចប្រជុំនាថ្ងៃនេះ និងបានជម្រាបជូនអំពីរបៀបវារៈនៃកិច្ចប្រជុំ ស្ថានភាពវិនិយោគដ៏ល្អប្រសើរនៅកម្ពុជា ជាពិសេសនៅក្នុងវិស័យយានយន្ត និងអេឡិចត្រូនិក ព្រមទាំងការត្រៀមខ្លួនរបស់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងការឆ្លើយតបនឹងការប្រែប្រួលនៃសភាពការណ៍ពាណិជ្ជកម្មពិភពលោកដែលអាចប៉ះពាល់ដល់បរិយាកាសវិនិយោគនៅកម្ពុជា។

បន្ថែមលើនេះទៀត ឯកឧត្តមអគ្គលេខាធិការ ក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា (IDP) ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី ក្នុងការឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចជាតិ និងចក្ខុវិស័យកម្ពុជា២០៥០ ហើយនៅក្នុងគោលនយោបាយនេះផងដែរ វិស័យយានយន្ត និងអេឡិចត្រូនិក ត្រូវបានចាត់ទុកជាវិស័យអាទិភាព និងជាកម្លាំងចលករដ៏សំខាន់ ក្នុងការចូលរួមជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្មទៅជាឧស្សាហកម្មដែលផ្អែកលើជំនាញ និងមានតម្លៃបន្ថែមខ្ពស់។

ក្នុងកិច្ចប្រជុំនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ ក្នុងនាមតំណាងលោកអ្នកឧកញ៉ាប្រធានសមាគមឧកញ៉ាកម្ពុជា បានមានមតិលើកឡើងនូវចំណុចសំខាន់អំពីបញ្ហាប្រឈមដែលវិនិយោគិនកំពុងព្រួយបារម្ភគឺធនធានពលកម្មជំនាញសម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងវិស័យអាទិភាពមួយចំនួនដូចជា វិស័យកសិកម្ម កសិឧស្សាហកម្ម ការកែច្នៃផលិតផលកសិកម្ម បច្ចេកទេសយានយន្ត និងអេឡិចត្រូនិកជាដើម ដោយអ្នកឧកញ៉ាបានបន្ថែមទៀតថានាពេលបច្ចុប្បន្ន សមាគមឧកញ៉ាកម្ពុជាដែលជាស្ថាប័នឯកជនដែលបណ្តុំដោយធុរជនមានសក្តានុពលបាននឹងកំពុងគ្រប់គ្រងលើសហគ្រាសប្រមាណជាង ៨០០ និងវិនិយោគលើពហុវិស័យនៅទូទាំងប្រទេសក៏កំពុងជួបប្រទះនូវកង្វះខាតធនធានពលកម្មជំនាញនេះដែរ ហេតុនេះ អ្នកឧកញ៉ា បានស្នើឱ្យមានការរៀបចំសិក្ខាសាលារួមគ្នាដើម្បីពិភាក្សាលើបញ្ហានេះនិងដោយមានការចូលរួមពីស្ថាប័នជំនាញដូចជាក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) ដើម្បីផ្តល់នូវហិរញ្ញប្បទានលើការបណ្តុះបណ្តាលធនធានពលកម្មជំនាញដើម្បីពង្រឹងសមត្ថភាពធនធានមនុស្សស្របទៅតាមតម្រូវរបស់វិស័យឯកជន។

កិច្ចប្រជុំខាងលើ បានប្រព្រឹត្តទៅដោយមានការចូលរួមមតិយោបល់យ៉ាងផុលផុសពីសមាជិក សមាជិកាអង្គប្រជុំ និងសម្រេចបាននូវលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់។ ទន្ទឹមនេះកិច្ចប្រជុំបានស្ទង់មតិអំពីការយល់ឃើញរបស់វិស័យឯកជនលើការរៀបចំ, ផលជះ និងប្រសិទ្ធភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិកកម្ពុជាផងដែរ។ ចំពោះទិសដៅការងារបន្ត ក.ប.យ.អ. នឹងពិនិត្យលើការធ្វើបច្ចុប្បន្នភាពសមាជិកឡើងវិញហើយគ្រោងនឹងរៀបចំកិច្ចប្រជុំលើកទី៤ នៅក្នុងអំឡុងពេល ៦ខែបន្ទាប់ខាងមុខ។

ថ្លែងក្នុងកិច្ចបិទអង្គប្រជុំនេះ ឯកឧត្តម ជា វុទ្ធី អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា បានសម្តែងនូវការវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការចូលរួមយ៉ាងសកម្មពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ, គ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាពិសេសវិស័យឯកជន ដែលនាំឱ្យដំណើរការនៃកិច្ចប្រជុំបានបញ្ចប់ទៅដោយរលូនប្រកបដោយជោគជ័យ និងទទួលបាននូវលទ្ធផលល្អតាមការរំពឹងទុក។









# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ អមដំណើរដោយថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបទៀត បានចូលរួមគោរពវិញ្ញាណក្ខន្ធមហាឧបាសក ឡាវ តេកសេង









នាថ្ងៃពុធ ៤កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវអមដំណើរដោយលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាជាច្រើនរូបទៀត បានចូលរួមគោរពវិញ្ញាណក្ខន្ធមហាឧបាសក ឡាវ តេកសេង ដែលត្រូវជាឪពុកបង្កើតរបស់អ្នកឧកញ៉ា ឡាវ កាង សមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមឧកញ៉ាកម្ពុជា ខណៈដែលពិធីបុណ្យសពកំពុងរៀបចំឡើងនាគេហដ្ឋានដែលស្ថិតនៅក្នុងភូមិ២ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

ក្នុងវេលាប្រកបដោយក្តីក្រៀមក្រំនេះ លោកអ្នកឧកញ៉ាប្រធាន បាននាំយកនូវលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនចំពោះអ្នកឧកញ៉ា ឡាវ កាង និងលោកជំទាវព្រមទាំងក្រុមគ្រួសារដោយក្តីអាឡោះអាល័យចំពោះការបាត់បង់ឪពុកបង្កើត ឪពុកក្មេក ជីតា ជីតាទួត ជាទីគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅនិងពោរពេញទៅដោយព្រហ្មវិហារធម៌ដែលបានលះបង់បូជាអស់កម្លាំងកាយ កម្លាំងចិត្តគ្រប់សព្វបែបយ៉ាងក្នុងការបីបាច់ថែរក្សា បុត្រា បុត្រី ចៅប្រុស ចៅស្រី ឱ្យក្លាយជាពលរដ្ឋដ៏ល្អសម្រាប់សង្គមជាតិ។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធ មហាឧបាសក ឡាវ តេកសេង សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបុណ្យសពសិរីសុមនាភិរ័ក្ខពង្សិណីអគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ នាង ខេង ដែលជាម្តាយបង្កើតរបស់អ្នកឧកញ៉ា តេង ហឿង

នារសៀលថ្ងៃអាទិត្យ ១៥កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា អមដំណើរដោយលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ជាច្រើនរូបទៀត បានចូលរួមពិធីបុណ្យសពសិរីសុមនាភិរ័ក្ខពង្សិណីអគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ នាង ខេង ដែលត្រូវជាម្តាយបង្កើតរបស់ អ្នកឧកញ៉ា តេង ហឿង សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា នាគេហដ្ឋាននៃសព។

ក្នុងវេលាប្រកបដោយក្តីក្រៀមក្រំនេះ លោកអ្នកឧកញ៉ាប្រធាន បាននាំយកនូវលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជា ជូនចំពោះអ្នកឧកញ៉ា តេង ហឿង និងលោកជំទាវព្រមទាំងក្រុមគ្រួសារដោយក្តីអាឡោះអាល័យចំពោះការបាត់បង់ម្តាយបង្កើត ម្តាយក្មេក ជីដូន ជីដូនទួត ជាទីគោរពស្រឡាញ់យ៉ាងជ្រាលជ្រៅនិងពោរពេញទៅដោយព្រហ្មវិហារធម៌ដែលបានលះបង់បូជាអស់កម្លាំងកាយ កម្លាំងចិត្តគ្រប់សព្វបែបយ៉ាងក្នុងការបីបាច់ថែរក្សា បុត្រា បុត្រី ចៅប្រុស ចៅស្រី ឱ្យក្លាយជាពលរដ្ឋដ៏ល្អសម្រាប់សង្គមជាតិ។

យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ សិរីសុមនាភិរ័ក្ខពង្សិណីអគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ នាង ខេង សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។















# ថ្នាក់ដឹកនាំនិងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ប្រគល់ថវិកាជូនកាកបាទក្រហមកម្ពុជាក្នុងឱកាសខួបលើកទី១៦២ ទិវាពិភពលោកកាកបាទក្រហម និង អឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៥ និងខួបលើកទី៧០ នៃកាកបាទក្រហមកម្ពុជា




នាថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ បានដឹកនាំប្រតិភូសមាគមឧកញ៉ាកម្ពុជាចំនួន ៧០រូបចូលរួមក្នុងពិធីសំណេះសំណាល និងប្រគល់-ទទួលថវិកាជូនកាកបាទក្រហមកម្ពុជាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា។

សូមបញ្ជាក់ថា នៅឆ្នាំ២០២៥នេះមានសមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន ១១៨នាក់បានចូលរួមបរិច្ចាគថវិកាជូនកាកបាទក្រហមកម្ពុជា តាមរយៈសមាគមដែលមានទឹកប្រាក់សរុប ១,៧១៦,៦៦៦ ដុល្លារអាមេរិក ក្នុងនោះប្រាក់រៀលសរុបចំនួន ៨០,៣៥៧,១១០ រៀល និងប្រាក់ដុល្លារសរុបចំនួន ១,៦៩៦,៥៧៦.៧២ ដុល្លារអាមេរិក។

ក្នុងឱកាសដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមក្នុងពិធីសំណេះសំណាល និងប្រគល់-ទទួលថវិកា ជូនកាកបាទក្រហមកម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានជម្រាបជូន **លោកជំទាវបណ្ឌិត** អំពីសកម្មភាពរបស់សមាគមឧកញ៉ាកម្ពុជាដែលបានចូលរួមជាមួយរាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាស្ថាប័នមនុស្សធម៌ជាច្រើនទៀតក្នុងគោលដៅរួមចំណែកលើការកសាងហេដ្ឋារចនាសម្ព័ន្ធនានាទាំងផ្នែកពុទ្ធចក្រ និងអាណាចក្រ ក៏ដូចជាសកម្មភាពធុរកិច្ចដើម្បីបង្កើតការងារជូនប្រជាពលរដ្ឋនៅទូទាំងប្រទេសផងដែរ។

ស្ថិតក្នុងឱកាសនេះដែរ **លោកជំទាវបណ្ឌិត** បានពាំនាំនូវព្រះរាជសវនីយ៍របស់ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ព្រះប្រធានកិត្តិយស និងប្រសាសន៍របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដែលបានផ្តាំផ្ញើសួរសុខទុក្ខ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាគមឧកញ៉ាកម្ពុជាដែលតែងតែបានចូលរួមបរិច្ចាគថវិកា និងសម្ភារៈ ជូនកាកបាទក្រហមកម្ពុជាដោយសទ្ធាជ្រះថ្លា និងតាមការស្ម័គ្រចិត្តជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០២៣មក ក៏ដូចជាតែងតែចូលរួមវិភាគទានក្នុងកម្មវិធីសប្បុរសធម៌ជាច្រើនទាំងក្នុងការងារសង្គម និងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលទាំងនេះបានឆ្លុះបញ្ចាំងពីការចូលរួមប្រកបដោយឆន្ទៈ និងបេះដូងមនុស្សធម៌ពិតៗរបស់សមាជិកសមាជិកានៃសមាគមឧកញ៉ាកម្ពុជាក្នុងការជួយដល់សង្គមជាតិរបស់យើង។



**លោកជំទាវបណ្ឌិត** ក៏បានជម្រាបជូនគណៈប្រតិភូផងដែរថា សកម្មភាពទាំងអស់របស់កាកបាទក្រហមកម្ពុជា គឺបានមកពីការជួយឧបត្ថម្ភគាំទ្រពីសំណាក់សប្បុរសជនគ្រប់មជ្ឈដ្ឋាន ទើបកាកបាទក្រហមកម្ពុជា អាចបំពេញបេសកកម្មមនុស្សធម៌បាន និងអាចបន្តនិរន្តរភាពទៅមុខទៀតបាន។

**លោកជំទាវបណ្ឌិត** ក៏បានគោរពជូនពរដល់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា សមាជិកសមាជិកានៃសមាគមឧកញ៉ាកម្ពុជា សូមមានសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ចជាបន្តបន្ទាប់ និងសង្ឃឹមជឿជាក់ថា សមាគម នឹងបន្តចូលរួមឧបត្ថម្ភគាំទ្រដល់កាកបាទក្រហមកម្ពុជានៅឆ្នាំក្រោយៗជាបន្តបន្ទាប់ទៀត។

ក្នុងឱកាសនោះដែរ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានសម្តែងនូវអារម្មណ៍រំភើប និងសប្បាយរីករាយជាខ្លាំងដែល **លោកជំទាវបណ្ឌិត** បានចំណាយពេលវេលាដ៏មមាញឹក និងមានតម្លៃផ្តល់កិត្តិយដល់សមាគមឧកញ៉ាកម្ពុជា បានចូលជួបសម្តែងការគួរសម និងចូលរួមបរិច្ចាគថវិកាជូនដល់កាកបាទក្រហមកម្ពុជា។ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានគោរពជូនពរជ័យសិរីមង្គលវិបុលសុខ មហាប្រសើរជូនចំពោះ **លោកជំទាវបណ្ឌិត** និង **សម្តេចធិបត** ព្រមទាំងបុត្រា បុត្រី សូមប្រកបដោយ បញ្ញាញាណភ្លឺថ្លាវាងវៃ កាយពលមាំមួន សុខភាពល្អបរិបូណ៌ និងជន្មាយុយឺនយូរ។





































## លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមក្នុងពិធីសម្ពោធបើកឱ្យដំណើរជាផ្លូវការ «រោងចក្រផលិតស៊ីម៉ងត៍របស់ក្រុមហ៊ុន ខនស៍ ខេធី ស៊ីមេន (ភ្នំពេញ) ឯ.ក»



នាថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីសម្ពោធបើកឱ្យដំណើរជាផ្លូវការ «រោងចក្រផលិតស៊ីម៉ងត៍របស់ក្រុមហ៊ុន ខនស៍ ខេធី ស៊ីមេន (ភ្នំពេញ) ឯ.ក» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ថា រោងចក្រស៊ីម៉ងត៍របស់ក្រុមហ៊ុន ខនស៍ ខេធី ស៊ីមេន (ភ្នំពេញ) ឯ.ក ស្ថិតនៅភូមិមនោរម្យ ឃុំហោងសំណំ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដែលមានសមត្ថភាពផលិតស៊ីម៉ងត៍ចំនួន ២,២លានតោនក្នុងមួយឆ្នាំ និងបង្កើតការងារផ្ទាល់ និងប្រយោលចំនួនជាង១០០០កន្លែង។

ក្រុមហ៊ុន ខនស៍ ស៊ីម៉ងត៍ ត្រូវបានបង្កើតក្រោមទុនវិនិយោគរួមគ្នារវាងវិនិយោគិចិន និងក្រុមហ៊ុន KT Pacific Group របស់កម្ពុជាដែលមានលោកអ្នកឧកញ៉ា ហុង ស៊ួន អនុប្រធានសមាគមឧកញ៉ាកម្ពុជា ជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ព្រមទាំងអ្នកឧកញ៉ាបណ្ឌិត វិញ ហ៊្សួរ អនុប្រធានសមាគមឧកញ៉ាកម្ពុជា ជាសហស្ថាបនិក និងអ្នកឧកញ៉ា ទីវ ម៉េងហ៊ុយ សមាជិកក្រុមប្រឹក្សាភិបាល នៃសមាគមឧកញ៉ាកម្ពុជា ជាគណៈគ្រប់គ្រងជាន់ខ្ពស់ផងដែរ។

គួរបញ្ជាក់ផងដែរថា នាពេលបច្ចុប្បន្នរោងចក្រ ខនស៍ ស៊ីម៉ងត៍ មានចំនួន ២កន្លែងដោយទីតាំងទី១ ស្ថិតនៅក្នុងស្រុករតនមណ្ឌល ខេត្តបាត់ដំបងនិងត្រូវបានសម្ពោធជាផ្លូវកាលពីឆ្នាំ២០១៨ ចំណែកឯរោងចក្រទី២ មានទីតាំងស្ថិតនៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺលើផ្ទៃដីសរុប ៤០៧ហិចតា។ រោងចក្រទាំងពីរនេះមានសមត្ថភាពផលិតសរុបប្រមាណ ៤.២លានតោនក្នុងឆ្នាំ និងបានផ្តល់ការងារដល់ប្រជាពលរដ្ឋខ្មែរជាច្រើនពាន់នាក់។













# សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានកិត្តិយសក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឱ្យ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ និងថ្នាក់ដឹកនាំ នៃសមាគមឧកញ៉ាកម្ពុជាអញ្ជើញចូលសួរសុខទុក្ខ និងគោរពជូនពរ

នាថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានកិត្តិយសក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជានិង **សម្តេចធម្មវិសុទ្ធវង្សា សៅ ទី** បានអនុញ្ញាតឱ្យលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា និងលោកជំទាវ ព្រមទាំងឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា ជាច្រើនរូបទៀតអញ្ជើញចូលសួរសុខទុក្ខនៅភូមិគ្រឹះចំការមននៅក្នុងឱកាសនៃទិវាជាតិនៃការចងចាំ និងអបអរសាទរថ្ងៃ៧ មករា កំណើតទី២ផងដែរ។

ក្នុងឱកាសដ៏ឧត្តុង្គឧត្តមនេះ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ និងលោកជំទាវ បានគោរពជូនពរសម្តេចទាំងទ្វេ និងក្រុមគ្រួសារជាទីស្រលាញ់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណវាងវៃ ព្រមទាំងវិបុលសុខគ្រប់ប្រការ។











# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអញ្ជើញចូលរួម កិច្ចប្រជុំកំពូលអាស៊ាន លើកទី៤៦ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ នៅប្រទេសម៉ាឡេស៊ី







ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានចាត់តាំងអ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធាន និងជាប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ ដើម្បីដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាអមដំណើរ **សម្តេចធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន លើកទី៤៦ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនៅប្រទេសម៉ាឡេស៊ីចាប់ពីថ្ងៃទី២៥-២៧ ខែឧសភា ឆ្នាំ២០២៥។

សូមបញ្ជាក់ថា ក្នុងបេសកកម្មនេះគណៈប្រតិភូនៃសមាគមឧកញ៉ាកម្ពុជាដឹកនាំដោយអ្នកឧកញ៉ា សៀ ឬទ្ធី និងមានសមាសភាពសរុបចំនួន ១៨រូបដោយបានចូលរួមជំនួបពិភាក្សាការងារជាបន្តបន្ទាប់ដូចជា៖

១. ជំនួបទទួលទានអាហារការងារពេលព្រឹករវាងធុរជនមកពីប្រទេសកម្ពុជា និងម៉ាឡេស៊ី ក្រោមអធិបតីភាពលោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយមានការចូលរួមពីអ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធានសមាគមឧកញ៉ាកម្ពុជា ព្រមទាំងអ្នកឧកញ៉ា ជាសមាជិកនៃគណៈប្រតិភូសមាគម ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបត្តិការធុរកិច្ចរវាងភាគីទាំងពីរផងដែរនាព្រឹកទី២៦ ខែឧសភា ឆ្នាំ២០២៥។

២. ជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាងគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា និងថ្នាក់ដឹកនាំក្រុមហ៊ុន Aurelius Healthcare ជាមួយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នាល្ងាចថ្ងៃអង្គារ ទី២៧ ខែឧសភា ឆ្នាំ២០២៥ ដោយគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដឹកនាំដោយអ្នកឧកញ៉ា សៀ ឬទ្ធី និងលោក Dato' Amir Firdaus Abdullah ប្រធាន និងជានាយកគ្រប់គ្រងក្រុមហ៊ុន Aurelius Healthcare ចូលសម្តែងការគួរសម និងពិភាក្សាការងារនាទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។ សូមបញ្ជាក់ថា ក្រុមហ៊ុន Aurelius Healthcare ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៩ ដោយមានគោលបំណងបង្កើតនូវទម្រង់នៃការថែទាំសុខភាពពិសេសមួយ ដើម្បីផ្តោតលើការថែទាំសុខភាពបែបឯកជនកម្រិតមធ្យម និងការផ្តល់សេវាថែទាំសុខភាពដោយសមធម៌សម្រាប់អ្នកជំងឺ និងបុគ្គលិកថែទាំសុខភាព។ ក្រុមហ៊ុន Aurelius Healthcare មានមន្ទីរពេទ្យ ដៃគូចំនួន៣ នៅប្រទេសម៉ាឡេស៊ី និងចំនួន៦ នៅឥណ្ឌូចិន ក្នុងនោះមានមន្ទីរពេទ្យចំនួន២ នៅប្រទេសកម្ពុជាដូចជា៖ មន្ទីរពេទ្យ Orienda International Hospital និងមន្ទីរពេទ្យ Orchid Koh Pich Hospital ដែលមានគ្រែសម្រាកព្យាបាលសរុបចំនួន១៧០ ។

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា អមដំណើរ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសជប៉ុន







ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានចាត់តាំងអ្នកឧកញ៉ា សៀ ឬទ្ធី អនុប្រធាន និងជាប្រធានគណៈកម្មការទំនាក់ទំនងសាធារណៈ និងអន្តរជាតិ ដើម្បីដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដែលមានសមាសភាពសរុបចំនួន១៨រូប ចូលរួមអមដំណើរ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងឱកាសអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅទីក្រុងតូក្យូ ប្រទេសជប៉ុនចាប់ថ្ងៃទី២៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៥។

នៅក្នុងបេសកកម្មនេះ គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាបានចូលរួមជំនួបពិភាក្សាការងារជាបន្តបន្ទាប់ដូចជាៈ

១. ជំនួបសម្តែងការគួរសមនិងពិភាក្សាការងាររវាងគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ដឹកនាំដោយអ្នកឧកញ៉ា សៀ ឬទ្ធី រួមទាំងលោក DEMIZU Shigemitsu ប្រធានក្រុមហ៊ុន YACHIYO Engineering Co., Ltd. និងសហការី ជាមួយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** នារសៀលថ្ងៃព្រហស្បតិ៍ ទី២៩ ខែឧសភា ឆ្នាំ២០២៥។ ក្នុងឱកាសនៃជំនួបនេះ លោកប្រធានក្រុមហ៊ុនបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចបវរធិបតី** ដែលបានចំណាយពេលវេលាដ៏មមាញឹក អនុញ្ញាតឱ្យរូបលោក និងសហការីបានចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។ លោកប្រធានក្រុមហ៊ុនក៏បានបង្ហាញជំនឿយ៉ាងមុតមាំថា ក្រោមការដឹកនាំរបស់ **សម្តេចបវរធិបតី** ប្រទេសកម្ពុជានឹងបន្តអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យបន្ថែមទៀតនាពេលអនាគត។ ជាមួយគ្នានេះ លោកប្រធានក្រុមហ៊ុនបានគោរពរាយការណ៍ជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** អំពីវឌ្ឍនភាពនៃដំណើរការនៃគម្រោងមួយចំនួនរបស់ក្រុមហ៊ុននៅកម្ពុជាពាក់ព័ន្ធនឹងការកែច្នៃសំណល់។ លោកក៏បានជម្រាបពីគោលបំណងពង្រីកការវិនិយោគរបស់ក្រុមហ៊ុនលើការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ក្នុងខេត្តព្រះសីហនុ ដោយបង្ហាញសុទិដ្ឋិនិយមថាការវិនិយោគនេះនឹងនាំមកជាមួយនូវបទពិសោធន៍ និងបច្ចេកវិទ្យាទំនើបមកកាន់ប្រទេសកម្ពុជា សំដៅរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ទន្ទឹមនឹងនេះ លោកប្រធានក្រុមហ៊ុនបានបន្តទៀតថា ក្រុមហ៊ុនមានបច្ចេកវិទ្យាទំនើបក្នុងការដោះស្រាយបញ្ហាជំងឺឆ្លងតាមទឹកកខ្វក់ ដែលនឹងរួមចំណែកលើកកម្ពស់សុខុមាលភាពប្រជាជនតាមរយៈការលើកកម្ពស់អនាម័យសាធារណៈក៏ដូចជាការចូលរួមអភិវឌ្ឍទីក្រុងឆ្លាត។

ជាការឆ្លើយតប **សម្តេចបវរធិបតី** បានសម្តែងការស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះក្រុមហ៊ុនដែលកំពុងវិនិយោគលើគម្រោងការកែច្នៃសំណល់នៅកម្ពុជា។ **សម្តេចបវរធិបតី** បានគូសបញ្ជាក់ថា សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋកម្ពុជាមិនខុសពីសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋជប៉ុននោះទេ ពោលគឺនៅពេលដែលកម្រិតជីវភាពប្រជាពលរដ្ឋកាន់តែរីកចម្រើន និងចំនួនប្រជាជនកាន់តែកើនឡើងតម្រូវការក្នុងការប្រើប្រាស់ទឹក និងការបញ្ចេញសំណល់ក៏កើនឡើងដូចគ្នាដែរ។

ក្នុងន័យនេះ ការវិនិយោគលើការកែច្នៃសំណល់ និងការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់ពិតជាមានភាពចាំបាច់ដើម្បីឆ្លើយតបនឹងតម្រូវការ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ។ **សម្តេចបវរធិបតី** ក៏បានបញ្ជាក់ថារាជរដ្ឋាភិបាលគាំទ្រគោលបំណងពង្រីកការវិនិយោគ និងកិច្ចសហប្រតិបត្តិការលើការធ្វើប្រព្រឹត្តកម្មទឹកកខ្វក់នេះ។**សម្តេចបវរធិបតី**បានលើកទឹកចិត្តឱ្យក្រុមហ៊ុនបន្តសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលខេត្តព្រះសីហនុផ្ទាល់។

២. ចូលរួមពិធីបើកវេទិកាធុរកិច្ចកម្ពុជា-ជប៉ុន ក្រោមអធិបតីភាព **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងមានការចូលរួមពីសំណាក់វិនិយោគិនកម្ពុជា និងជប៉ុនចំនួនជិត៣០០នាក់មកពីបណ្តាក្រុមហ៊ុនចំនួន ២២៧ ក្រុមហ៊ុននាល្ងាចថ្ងៃព្រហស្បតិ៍ ទី២៩ ខែឧសភា ឆ្នាំ២០២៥។ សូមបញ្ជាក់ថា វេទិកានេះត្រូវបានសហការរៀបចំដោយ សភាពាណិជ្ជកម្មកម្ពុជា អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុន (JETRO) គណៈកម្មាធិការសហប្រតិបត្តិការសេដ្ឋកិច្ចនិងឧស្សាហកម្មជប៉ុន (AMEICC) និងធនាគារមីស៊ូហ៊ុ (Mizuho) នៅទីក្រុងតូក្យូ ប្រទេសជប៉ុន។










៣. រៀបចំកម្មវិធីផ្គូផ្គងវិនិយោគរវាងសមាគមឧកញ៉ាកម្ពុជាជាមួយធុរជន និងថ្នាក់ដឹកនាំក្រុមហ៊ុនសំខាន់ៗរបស់ជប៉ុននាល្ងាចថ្ងៃព្រហស្បតិ៍ ទី២៩ ខែឧសភា ឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តម ស៊ុន ចាន់ថុល ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងគោលបំណងពិភាក្សាការងារក៏ដូចជាផ្សព្វផ្សាយនូវព័ត៌មាននិងកាលានុវត្តន៍ភាពក្នុងវិស័យអាទិភាពសំខាន់ៗរបស់កម្ពុជាដែលកំពុងរង់ចាំវិនិយោគិនពីគ្រប់ទិសទីជាពិសេសវិនិយោគិនជប៉ុនតែម្តង។

ក្នុងឱកាសនេះដែរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍ថា ការប្រើប្រាស់បច្ចេកវិទ្យាជឿនលឿននឹងមានប្រសិទ្ធភាពសម្រាប់លើកកម្ពស់ផលិតភាពក្នុងខ្សែច្រវាក់ផលិត ដោយធ្វើអានុភាវូបនីយកម្មគោលនយោបាយនានាពាក់ព័ន្ធនឹងវិនិយោគប្រកបដោយភាពអនុគ្រោះសម្រាប់ជំរុញការវិនិយោគឱ្យកាន់តែមានប្រសិទ្ធផលសេដ្ឋកិច្ចខ្ពស់។ ជាមួយគ្នានេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានជំរុញលើកទឹកចិត្តឱ្យវិនិយោគិនជប៉ុនពិចារណាពិនិត្យលទ្ធភាពក្នុងការពង្រីកមូលដ្ឋានផលិតកម្មរបស់ខ្លួនមកកម្ពុជាផងដែរ ដើម្បីច្បាមយកផលប្រយោជន៍ពីយុទ្ធសាស្ត្រប្រទេសបូក ដូចជា ថៃបូកមួយ ចិនបូកមួយ វៀតណាមបូកមួយ ។ល។ ខណៈដែលកម្ពុជាកំពុងឈរជើងយ៉ាងរឹងមាំលើមូលដ្ឋានសំខាន់ទាំងបីគឺ៖ (១) ការតាំងទីនៅត្រង់ចំណុចកណ្តាលបេះដូងនៃតំបន់អាស៊ានដែលមានការអភិវឌ្ឍប្រកបដោយថាមវន្ត, (២) ទីតាំងអំណោយផលក្នុងអភិក្រមអបធុរកិច្ចដែលរាជរដ្ឋាភិបាលបានកំណត់យកជាអភិក្រមធ្វើការរួមគ្នាជាមួយផ្នែកឯកជន សំដៅជំរុញក្បាលម៉ាស៊ីនកំណើនសេដ្ឋកិច្ច ដើម្បីវិបុលភាពរួមព្រមទាំងគោលនយោបាយវិនិយោគផ្តោតលើអភិក្រមផ្តល់កិច្ចសម្រួលវិនិយោគកាន់តែងាយស្រួល សាមញ្ញ ឆាប់រហ័ស, និង (៣) ការផ្តល់កញ្ចប់លើកទឹកចិត្តវិនិយោគប្រកបដោយភាពឆ្លាតវៃនិងមានភាពប្រកួតប្រជែងជាមួយនឹងឧត្តមភាពប្រៀបធៀបខ្ពស់នៅក្នុងតំបន់ ហើយថែមទាំងផ្តល់នូវសេវាថែទាំគាំទ្រវិនិយោគដ៏កក់ក្តៅជូនដល់វិនិយោគិនថែមទៀតផង។

ជាមួយគ្នានេះ គណៈប្រតិភូនៃសមាគមឧកញ៉ាកម្ពុជា ក៏បានជម្រាបជូនបណ្តាធុរជន និងវិនិយោគិនជប៉ុនអំពីតួនាទីរបស់សមាគមឧកញ៉ាកម្ពុជា ដែលជាដៃគូមួយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងសកម្មភាពពាណិជ្ជកម្ម និងជំរុញវិនិយោគសំដៅបង្កើតការងារជូនប្រជាពលរដ្ឋ។ ទន្ទឹម នឹងនេះ ក៏បានលើកឡើងនូវបទពិសោធជាក់ស្តែងក្នុងនាមជាធុរជនដែលកំពុងប្រកបអាជីវកម្មនៅក្នុងប្រទេសកម្ពុជាអំពីលទ្ធផលក៏ដូចជាកត្តាអំណោយផល បរិយាកាសវិនិយោគនិងសក្តានុពលនានាដែលប្រទេសកម្ពុជាមានទាំងលើវិស័យកសិពាណិជ្ជកម្ម ថាមពល និង









# អ្នកឧកញ៉ា ទី ពិសិដ្ឋ សមាជិកក្រុមប្រឹក្សាភិបាល ដឹកនាំ សមាជិកសមាគមឧកញ៉ាកម្ពុជា ចូលរួមជំនួបពាណិជ្ជកម្មកម្ពុជា-កាណាដា

ថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៥ អ្នកឧកញ៉ា ទី ពិសិដ្ឋ សមាជិកក្រុមប្រឹក្សាភិបាលតំណាងលោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំសមាជិកចំនួន២០រូប ចូលរួមជាកិត្តិយសក្នុង "ជំនួបពាណិជ្ជកម្មកម្ពុជា-កាណាដា" ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ សុក ស៊ីផាន់ណា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការផ្តល់យោបល់លើគោលនយោបាយពាណិជ្ជកម្ម និងលោកជំទាវ Sara Wilshaw ប្រធានស្នងការពាណិជ្ជកម្មនៃប្រទេសកាណាដា និងជាឧបការីអនុរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មអន្តរជាតិ ដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នរដ្ឋ សភាពាណិជ្ជកម្ម សមាគម វិស័យឯកជន និងភាគីពាក់ព័ន្ធជាច្រើន។

ជំនួបពាណិជ្ជកម្មនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងស្វែងយល់ជាក់ស្តែងអំពីបរិយាកាសធុរកិច្ច និងស្វែងរកកាលានុវត្តភាពធុរកិច្ច និងភាពជាដៃគូវិនិយោគនៅកម្ពុជាផងដែរ ជាពិសេសក្នុងវិស័យ កសិ-ឧស្សាហកម្ម ការកែច្នៃម្ហូបអាហារ បច្ចេកវិទ្យាស្អាត និងហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាព។

សូមជម្រាបផងដែរថា ក្នុងគោលបំណងពង្រឹងនិងពង្រីកទំនាក់ទំនងនិងជំរុញកំណើនពាណិជ្ជកម្មរវាងកម្ពុជានិងកាណាដា លោកជំទាវ Sara Wilshaw បានដឹកនាំគណៈប្រតិភូវិនិយោគិនកាណាដាមកបំពេញទស្សនកិច្ច (2025 Team Canada Trade Mission - TCTM) នៅក្នុងប្រទេសកម្ពុជា និងថៃ ចាប់ពីថ្ងៃទី២៨ ដល់៣០ ខែឧសភា ឆ្នាំ២០២៥ ក្នុងនោះគណៈប្រតិភូរួមមានតំណាងជាង ៩០នាក់ មកពីក្រុមហ៊ុន និងស្ថាប័នកាណាដាជាង៥០ ហើយ៧០ភាគរយគឺជាសហគ្រាសធុនតូច និងមធ្យម។

បេសកកម្មនេះ គឺជាគំនិតផ្តួចផ្តើមដ៏សំខាន់មួយក្រោមយុទ្ធសាស្ត្រឥណ្ឌូប៉ាស៊ីហ្វិក និងយុទ្ធសាស្ត្រពិពិធកម្មពាណិជ្ជកម្មរបស់កាណាដា ជាមួយគោលបំណងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តាមរយៈការសិក្សាស្វែងយល់ពីបរិយាកាសវិនិយោគ ឱកាសពាណិជ្ជកម្មខ្សែច្រវាក់ផ្គត់ផ្គង់ និងបង្កើតភាពជាដៃគូរយៈពេលវែងប្រកបដោយបរិយាប័ន្ននៅក្នុងវិស័យពាក់ព័ន្ធសំខាន់ៗ។ ទស្សនកិច្ចនេះដែរ ត្រូវបានរៀបចំឡើងបន្ទាប់ពី ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស៊ុន ចាន់ថុល បានដឹកនាំគណៈប្រតិភូកម្ពុជា ដែលរួមមានប្រតិភូសមាគមឧកញ៉ាកម្ពុជាចូលរួមផងដែរក្នុងបេសកកម្មទាក់ទាញ និងជំរុញវិនិយោគនៅសហរដ្ឋអាម៉េរិក និងប្រទេសកាណាដា កាលពីថ្ងៃទី២២ ខែកញ្ញា ដល់ថ្ងៃទី៣ ខែតុលា ឆ្នាំ២០២៤ កន្លងទៅ។













# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា ដឹកនាំអ្នកឧកញ៉ា ឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិក នៃសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីបើកយុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់»












នាថ្ងៃអាទិត្យ ៦កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ា បានដឹកនាំ អ្នកឧកញ៉ា ឧកញ៉ា ដែលជាសមាជិកនៃសមាគមឧកញ៉ាកម្ពុជាក្នុងចូលរួមពិធីបើកយុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់» របស់មូលនិធិគន្ធបុប្ផាកម្ពុជា ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **លោកជំទាវបណ្ឌិត ពេជ ចន្ទ មុន្នី ហ៊ុនម៉ាណែត** ប្រធានកិត្តិយសមូលនិធិគន្ធបុប្ផា នាបរិវេណរូបសំណាកលោកយាយពេញ ខាងត្បូងរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រវត្តភ្នំ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា បានបញ្ជាក់ថា សម្រាប់ឆ្នាំ២០២៥ គឺជាលើកទី៤ហើយដែលយុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់» បានប្រារព្ធឡើងក្រោមការផ្តួចផ្តើម និងដឹកនាំដោយ **លោកជំទាវបណ្ឌិត** ដោយកាលពីឆ្នាំ២០២៤កន្លងមកទទួលបានលទ្ធផលដ៏ជោគជ័យដោយមានការចូលរួមបរិច្ចាគពីសប្បុរសជនជាង ២០ម៉ឺននាក់និងទទួលបានថវិកាសរុបជាង ៣,៣លានដុល្លារអាម៉េរិក។

ក្នុងឱកាសនេះដែរ **លោកជំទាវបណ្ឌិត** ប្រធានកិត្តិយសមូលនិធិគន្ធបុប្ផាកម្ពុជា បានមានប្រសាសន៍ថា នេះជាយុទ្ធនាការប្រចាំឆ្នាំដ៏សំខាន់មួយរបស់មូលនិធិគន្ធបុប្ផាកម្ពុជា ដើម្បីចូលរួមអបអរសាទរ ទិវាកុមារអន្តរជាតិ ១មិថុនា និងបំផុសស្មារតី «ខ្មែរជួយខ្មែរ» ក៏ដូចជាការផ្សារភ្ជាប់សាធារណជនជាសប្បុរសជនទាំងក្នុងនិងក្រៅប្រទេសឱ្យមានការចូលរួមបរិច្ចាគជូនមូលនិធិគន្ធបុប្ផាកម្ពុជាដើម្បីជួយសង្គ្រោះកុមារដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យគន្ធបុប្ផាទាំងក្នុងរាជធានីភ្នំពេញ និងខេត្តសៀមរាប ខណៈដែលការចំណាយប្រចាំថ្ងៃប្រមាណជា ១២ម៉ឺនដុល្លារ និងជាង៤៣លានដុល្លារនៅក្នុងមួយឆ្នាំ។

សូមបញ្ជាក់ដែរថា ក្នុងស្មារតីចូលរួមគាំទ្រសកម្មភាពសប្បុរិសធម៌ស្របទៅតាមទស្សនវិស័យ និងបេសកកម្មរបស់សមាគមឧកញ៉ាកម្ពុជា លោកអ្នកឧកញ៉ា លី យ៉ុងផាត់ បាននឹងកំពុងធ្វើការអំពាវនាវដល់ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ជាថ្នាក់ដឹកនាំ និងសមាជិកនៃសមាគមឧកញ៉ាកម្ពុជាដើម្បីរួមគ្នាបរិច្ចាគក្នុងយុទ្ធនាការ «១ម៉ឺនរៀល ១ម៉ឺននាក់» នេះផងដែរ។

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការ ចូលរួមក្នុងកម្មវិធីផ្លាស់ប្តូរសហគ្រិនវ័យក្មេង កម្ពុជា-ចិន ឆ្នាំ២០២៥ តាមសំណើរបស់ ផ្ទះយុវជនមិត្តភាពកម្ពុជា-ចិន



យោងតាមសំណើរបស់ ផ្ទះយុវជនមិត្តភាពកម្ពុជា-ចិន លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការចូលរួមជាមួយគណៈប្រតិភូកម្ពុជាដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរសហគ្រិនវ័យក្មេងកម្ពុជា-ចិន ឆ្នាំ២០២៥ ចាប់ពីថ្ងៃទី១៩-២៩ ខែឧសភា ឆ្នាំ២០២៥ នៅរដ្ឋធានីប៉េកាំង ក្រុងដាលាន និងក្រុងសិនជិន សាធារណរដ្ឋប្រជាមានិតចិន។

ក្រោមការដឹកនាំដោយឯកឧត្តម គីម រិទ្ធី ប្រធានក្រុមប្រឹក្សាភិបាល ផ្ទះយុវជនដើម្បីមិត្តភាពកម្ពុជា-ចិន គណៈប្រតិភូកម្ពុជា បានចូលរួមក្នុងកម្មវិធីសំខាន់ៗជាបន្តបន្ទាប់រួមទាំងជំនួបសម្តែងការគួរសមជាមួយថ្នាក់ដឹកនាំចិន ក៏ដូចជាដំណើរទស្សនកិច្ចនាទីក្រុងប៉េកាំង ក្រុងដាលាន និងក្រុងសិនជិន ក្នុងគោលបំណងភ្ជាប់ទំនាក់ទំនងរវាងអ្នកជំនួញរួមទាំងសហគ្រិននៃប្រទេសទាំងពីរដើម្បីរួមគ្នាអភិវឌ្ឍ និងជំរុញការវិនិយោគ ប្រកបដោយសក្តានុពលទាំងពេលបច្ចុប្បន្ន និងអនាគត។

គណៈប្រតិភូកម្ពុជាទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅជាក់ស្តែងនាថ្ងៃទី១៩ ឧសភា ឆ្នាំ២០២៥ ឯកឧត្តម លីវ ជានឆាវ រដ្ឋមន្ត្រីទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ នៃគណៈកម្មាធិការកណ្តាលគណៈបក្សកុម្មុយនីស្តចិន បានអនុញ្ញាតដល់ ឯកឧត្តម គីម រិទ្ធី ដឹកនាំគណៈប្រតិភូកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារដោយបានផ្តោតលើកិច្ចពិភាក្សាក្នុងការធ្វើឱ្យស៊ីជម្រៅនូវការផ្លាស់ប្តូរថ្នាក់ដឹកនាំវ័យក្មេង សហគ្រិនវ័យក្មេង និងយុវជន ដើម្បីពង្រឹងទំនាក់ទំនង សិក្សាស្វែងយល់បង្កើនកិច្ចសហប្រតិបត្តិការ ក៏ដូចជាជំរុញការយល់ដឹងគ្នាទៅវិញទៅមករវាងកម្ពុជា និងចិន។





ក្នុងឱកាសបំពេញបេសកកម្មនេះដែរ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានជម្រាបជូន ឯកឧត្តម លីវ ជានឆាវ នូវសារតាសង្ខេបរបស់សមាគមឧកញ៉ាកម្ពុជា រួមជាមួយតួនាទីស្នូល និងសកម្មភាពរបស់សមាគមឧកញ៉ា។ បន្ថែមពីលើនេះ អ្នកឧកញ៉ា ក៏បានជូនឯកឧត្តម លីវ ជានឆាវ រួមមានសៀវភៅឧកញ៉ា ឆ្នាំ២០២៥ ជាភាសាចិន រួមជាមួយផលិតផលកែច្នៃរួចដ៏មានសក្តានុពលរបស់កម្ពុជាដូចជាគ្រាប់ស្វាយចន្ទី ដំណាប់ស្វាយកែវរមៀត ស្ករត្នោតសរីរាង្គកំពង់ស្ពឺ (GI) ផងដែរ។

នាថ្ងៃបន្តបន្ទាប់មកទៀត គណៈប្រតិភូផ្ទះយុវជនក៏បានជួបពិភាក្សាការងារជាមួយបណ្តាថ្នាក់ដឹកនាំជាច្រើនរួមមាន៖

១. ជំនួបជាមួយឯកឧត្តម Tan Zuojun អនុប្រធានគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន (SASAC) ដែលឯកឧត្តមបានវាយតម្លៃខ្ពស់អំពីទំនាក់ទំនងនៃប្រទេសទាំងពីរចាប់តាំងពីយូរលង់ណាស់មកហើយដែលត្រូវបានថែរក្សាបន្តដោយយុវជនជំនាន់ក្រោយ ក្នុងនោះផ្ទះយុវជនជាយន្តការមួយដែលកំពុងដើរតួនាទីក្នុងការពង្រឹង និងពង្រីកទំនាក់ទំនងរវាងថ្នាក់ដឹកនាំវ័យក្មេង និងយុវជននៃប្រទេសទាំងពីរ។

២. ដំណើរបំពេញទស្សនកិច្ចផ្លូវការនៅទីស្នាក់ការកណ្តាលរបស់មូលនិធិចិនសម្រាប់សន្តិភាព និងការអភិវឌ្ឍ (CFPD) នៅទីក្រុងប៉េកាំង ប្រទេសចិន។

៣. ដំណើរទស្សនកិច្ចស្វែងយល់ពីបច្ចេកវិទ្យាអប់រំជឿនលឿននៅសាកលវិទ្យាល័យបច្ចេកវិទ្យា និងធុរកិច្ចប៉េកាំង (Beijing Technology and Business University –BTBU)

៤. ទស្សនកិច្ច និងសិក្សាស្វែងយល់អំពីការអភិវឌ្ឍរថភ្លើងរៀបចំដោយក្រុមហ៊ុនរថភ្លើងល្បឿនលឿនរបស់ចិន China Railway High-Speed (CRH)

៥. ជំនួបសម្តែងការគួរសមជាមួយ ឯកឧត្តម ឈិន ពូអ៊ី សមាជិកអចិន្ត្រៃយ៍ និងជាប្រធានផ្នែកចាត់តាំងនៃគណៈកម្មាធិការក្រុងសិនជិនដើម្បីជំរុញកិច្ចសហប្រតិបត្តិការកាន់តែច្រើនទៀតជាមួយកម្ពុជាលើវិស័យបច្ចេកវិទ្យាឌីជីថលឈានមុខ ឧបករណ៍អេឡិកត្រូនិក ពាណិជ្ជកម្ម និងវិនិយោគ និងដំណើទស្សនកិច្ចសិក្សាស្វែងយល់ដោយផ្ទាល់ពីការអភិវឌ្ឍសួនឧស្សាហកម្មនាសម័យបច្ចេកវិទ្យាជឿនលឿនដែលជាផ្នែកដ៏សំខាន់មួយសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច បង្កើនទំនាក់ទំនងជាលក្ខណៈអន្តរជាតិនៅទីក្រុងជូហាយ និងសិនជិន។



















តាមរយៈបេសកកម្មនេះ សហគ្រិនកម្ពុជាបានចូលរួមកិច្ចប្រជុំកម្រិតខ្ពស់ជាច្រើនរួមទាំងទស្សនកិច្ចសិក្សា បទបង្ហាញតាមប្រធានបទ និងការផ្លាស់ប្តូរវប្បធម៌ដែលផ្តល់មេរៀនដ៏មានតម្លៃអំពីការអភិវឌ្ឍ ការដឹកនាំ កំណើនសេដ្ឋកិច្ចដែលជំរុញដោយការបង្កើតថ្មី និងកិច្ចសហប្រតិបត្តិការឆ្លងព្រំដែន ជាពិសេសអំពីសម្ព័ន្ធភាពជាយុទ្ធសាស្ត្រដើម្បីជំរុញការតភ្ជាប់ប្រទេសចិនទៅកាន់ពិភពលោកជាពិសេសជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ានផងដែរ។

ដូច្នេះ កម្មវិធីនេះមិនគ្រាន់តែជាបេសកកម្មការទូត ឬដំណើរទស្សនកិច្ចសិក្សានោះទេ វាគឺជាបទពិសោធនៃភាពជាអ្នកដឹកនាំដែលរៀបចំឡើងដើម្បីតម្រង់ទិសសហគ្រិនជំនាន់ថ្មីដែលមានគំនិតច្នៃប្រឌិតទូទាំងពិភពលោក និងការទទួលខុសត្រូវចំពោះសង្គមក៏ដូចជាការបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងធុរជន និងសហគ្រិន នៃប្រទេសទាំងពីរ។

# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចុះសួរសុខទុក្ខ និងនាំយកថវិកា សម្ភារៈ និងគ្រឿងឧបភោគបរិភោគមួយចំនួនប្រគល់ជូន កងទ័ពដែលកំពុងឈរជើងនៅជួរមុខការពារព្រំដែនកម្ពុជា-ថៃ ទិសទី១ ខេត្តព្រះវិហារ

នាព្រឹកថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ារួមមាន អ្នកឧកញ៉ា និងឧកញ៉ា ជាច្រើនរូបចូលរួមក្នុងដំណើរចុះសួរសុខទុក្ខ និងនាំយកថវិកា សម្ភារៈ និងគ្រឿងឧបភោគបរិភោគមួយចំនួនប្រគល់ជូន កងទ័ពដែលកំពុងឈរជើងនៅជួរមុខការពារព្រំដែនកម្ពុជា-ថៃ ទិសទី១ ខេត្តព្រះវិហារ ក្រោមការដឹកនាំដោយឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិបណ្ឌិត ហ៊ីង ប៊ុនហៀង អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការ នៃបញ្ជាការដ្ឋានអង្គរក្ស។


















សូមបញ្ជាក់ថា សមាជិកសមាគមឧកញ៉ាកម្ពុជាចំនួន ៨៥រូបបានរួមគ្នាឧបត្ថម្ភជាថវិកា សម្ភារៈ និងគ្រឿងឧបភោគបរិភោគដើម្បីសម្តែងក្តីស្រឡាញ់រាប់អាន និងដឹងគុណចំពោះវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពទាំងអស់ដែលលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីការពារទឹកដី និងការពារសេចក្តីសុខរបស់ប្រជាពលរដ្ឋទូទាំងប្រទេសដែលមានដូចជា៖

១- អំណោយជាថវិកាមាន ៖

- ជាប្រាក់ដុល្លារចំនួន ២០៥,៧៦៥ ដុល្លារអាម៉េរិក
- ជាប្រាក់រៀលចំនួន ៩៤លាន ១សែនរៀល

២- អំណោយជាគ្រឿងឧបភោគបរិភោគរួមមាន ៖

- ទឹកបរិសុទ្ធឱ៉ាល់ ១,៥០០ កេស (ឧបត្ថម្ភដោយ ក្រុមហ៊ុន យី តាក់ គ្រុប)
- មីក្រហម ១,០០០ កេស (ឧបត្ថម្ភដោយក្រុមហ៊ុន អិល វ៉ាយ ភី គ្រុប)
- ត្រី ខ កំប៉ុង ៥០០ កេស (ឧបត្ថម្ភដោយក្រុមហ៊ុន អិល វ៉ាយ ភី គ្រុប)
- ទឹកអង់ទីអុកស៊ីដង់ធម្មជាតិ ៣៥០កេស (ឧបត្ថម្ភដោយអ្នកឧកញ៉ា ឡេង ហ៊ួរ)
- ភេសជ្ជៈផៅវ័ររេម ៤,០០០ កេស (ឧបត្ថម្ភដោយ ក្រុមហ៊ុន ស៊ី ភី & អេ ត្រេឌីងអ៊ីនធើ ណេសិនណល)
- ចេកអំបូងលឿង ៦០កេស (ឧបត្ថម្ភដោយក្រុមហ៊ុនចម្ការកៅស៊ូ បឹងកេត)
- ប្រេងម៉ាស៊ីន ៤ធុងធំស្មើនឹង ៨៣៦លីត្រ (ឧបត្ថម្ភដោយក្រុមហ៊ុន ប្រេងម៉ាស៊ីន អ៊ីណូស)
- សាប៊ូកក់សក់ ខូស ម៉ូមិន ២៩៩ដប និងហ្វូមលាងមុខ ខស ឈេង ២៩០ទីប (ឧបត្ថម្ភដោយ អ្នកឧកញ៉ា ខុង លីស៊ីអាណា)

ក្នុងឱកាសនេះដែរ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ បានចាត់ អ្នកឧកញ៉ា ផៃ ហុកឈួន ប្រធានគណៈកម្មការរដ្ឋបាល និងហិរញ្ញវត្ថុ ឡើងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ា ទាំងអស់ដែលបានបរិច្ចាគថវិកា សម្ភារៈ និងគ្រឿងឧបភោគបរិភោគដូចបានរៀបរាប់ខាងលើដើម្បីជួយដល់កងទ័ពនាថ្ងៃនេះ ព្រមទាំងបានថ្លែងកោតសរសើរ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពជួរមុខទាំងអស់ដែលបានលះបង់គ្រប់បែបយ៉ាងដើម្បីជាតិ មាតុភូមិ និងប្រជាជន។

# អ្នកឧកញ៉ា ទី គីមស្រ៊ាន សមាជិកក្រុមប្រឹក្សាភិបាលជាតំណាង លោកអ្នកឧកញ៉ា លី យ៉ុងផាត់ប្រធានសមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីគោរពវិញ្ញាណក្ខន្ធឧបាសក តាំង គីមស្រេង ដែលត្រូវជាឪពុកក្មេករបស់ឧកញ៉ា ឈិន សុង














នាថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានចាត់តាំង អ្នកឧកញ៉ា ទី គីមស្រ៊ាន សមាជិកក្រុមប្រឹក្សាភិបាលជាតំណាងដើម្បីដឹកនាំអ្នកឧកញ៉ា ឧកញ៉ា និងក្រុមការងារ ចូលរួមក្នុងពិធីគោរពវិញ្ញាណក្ខន្ធឧបាសក តាំង គីមស្រេង ដែលត្រូវជាឪពុកក្មេករបស់ឧកញ៉ា ឈិន សុង សមាជិកសមាគមឧកញ៉ាកម្ពុជា ដែលកំពុងប្រារព្ធពិធីបុណ្យនាគេហដ្ឋានដែលស្ថិតនៅភូមិត្រពាំងត្រគៀត ឃុំពោធិអង្រ្គង ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

ក្នុងវេលាដ៏ក្រៀមក្រំនេះដែរ អ្នកឧកញ៉ា ទី គីមស្រ៊ាន បានពាំនាំនូវការចូលរួមរំលែកទុក្ខពីលោកអ្នកឧកញ៉ាប្រធាន ក៏ដូចជាលិខិតរំលែកមរណទុក្ខពីសមាគមឧកញ៉ាកម្ពុជាជូនចំពោះឧកញ៉ា ឈិន សុង និងលោកជំទាវ តាំង ហ្គេចសៀម ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ឧបាសក តាំង គីមស្រេង ដែលជាឪពុកបង្កើត ឪពុកក្មេក និងជីតា ប្រកបដោយព្រហ្មវិហារធម៌មួយរូប។

សូមឧទ្ទិសបបួងសួងដល់ដួងវិញ្ញាណក្ខន្ធ ឧបាសក តាំង គីមស្រេង សូមបានបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

# គណៈប្រតិភូសមាគមឧកញ៉ាកម្ពុជា ចូលរួម "ជំនួបផ្គូផ្គងធុរកិច្ចឥណ្ឌា-កម្ពុជា" ដើម្បីកសាងទំនាក់ទំនងធុរកិច្ច និងស្វែងរកឱកាសចាប់ដៃគូវិនិយោគ

នាថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥ សមាជិកសមាគមឧកញ៉ាកម្ពុជា បានចូលរួម "ជំនួបផ្គូផ្គងធុរកិច្ចឥណ្ឌា-កម្ពុជា" ដែលបានប្រព្រឹត្តទៅនៅសណ្ឋាគារសាងគ្រីឡា ភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសភាចារ្យ សុក ស៊ីផាន់ណា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មាធិការផ្តល់យោបល់លើគោលនយោបាយពាណិជ្ជកម្ម និង ឯកឧត្តម Vanlalvawna Bawitlung ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋឥណ្ឌាប្រចាំកម្ពុជា ដោយមានការចូលរួមពីតំណាងក្រសួង-ស្ថាប័នរដ្ឋ សភាពាណិជ្ជកម្ម សមាគម វិស័យឯកជន និងភាគីពាក់ព័ន្ធជាច្រើនរូប។

គោលបំណងនៃជំនួបផ្គូផ្គងធុរកិច្ចនេះ គឺដើម្បីជាវេទិកាសម្រាប់ពាណិជ្ជករកម្ពុជា និងឥណ្ឌា ជួបជុំគ្នាកសាងទំនាក់ទំនងធុរកិច្ច និងស្វែងរកឱកាសចាប់ដៃគូវិនិយោគទៅវិញទៅមកក្នុងវិស័យអាទិភាពនានា ដូចជាកសិកម្ម ការកែច្នៃផលិតផលកសិ-ឧស្សាហកម្ម សេវាហិរញ្ញវត្ថុ វេជ្ជសាស្ត្រ មន្ទីរពេទ្យ និងគ្រឿងអេឡិកត្រូនិចជាដើម។

សូមជម្រាបផងដែរថា លោកបណ្ឌិត Rajeev Singh Tyagi អគ្គនាយកនៃសភាពាណិជ្ជកម្មឥណ្ឌា បានដឹកនាំប្រតិភូធុរកិច្ចឥណ្ឌាចំនួន ២១ក្រុមហ៊ុន មកបំពេញទស្សនកិច្ចនៅកម្ពុជា ចាប់ពីថ្ងៃទី១៦-១៧ ខែមិថុនា ឆ្នាំ២០២៥ ក្នុងគោលបំណងសិក្សាស្វែងយល់ពីបរិយាកាសធុរកិច្ច ឱកាសពាណិជ្ជកម្ម និងស្វែងរកដៃគូវិនិយោគនៅកម្ពុជា នៅក្នុងវិស័យសំខាន់ៗខាងលើ។ ក្រៅពីជំនួបផ្គូផ្គងធុរកិច្ចនេះ ប្រតិភូធុរកិច្ចឥណ្ឌាក៏បានចុះទស្សនកិច្ចផ្ទាល់នៅកសិដ្ឋានកសិកម្មក៏ដូចជារោងចក្រកែច្នៃគ្រាប់ស្វាយចន្ទី ដើម្បីសិក្សាស្វែងយល់អំពីខ្សែច្រវាក់ផលិតកម្ម និងផ្គត់ផ្គង់ឱ្យកាន់តែមានភាពស៊ីជម្រៅផងដែរ។


















# លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ដឹកនាំគណៈប្រតិភូ សមាគមឧកញ៉ាកម្ពុជា ចូលរួមពិធីអបអរសាទរការដំណើរការជាផ្លូវការ ១ឆ្នាំ របស់សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា

នាថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៥ លោកអ្នកឧកញ៉ា លី យ៉ុងផាត់ ប្រធានសមាគមឧកញ៉ាកម្ពុជា បានដឹកនាំគណៈប្រតិភូសមាគមឧកញ៉ាកម្ពុជាដែលរួមមានវត្តមានលោកអ្នកឧកញ៉ា អ្នកឧកញ៉ា និងឧកញ៉ាជាច្រើនរូបចូលរួមក្នុងពិធីអបអរសាទរការដំណើរការជាផ្លូវការ ១ឆ្នាំរបស់សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិធីពិសាភោជនាហារសាមគ្គី ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

សូមបញ្ជាក់ថា សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា បានចងក្រងប្រមូលផ្តុំនូវសមាសភាពសមាគមនីមួយៗឱ្យរួមគ្នាជាថ្នាលធំមួយ ដើម្បីពង្រឹង និងពង្រីកសកម្មភាពទាក់ទាញវិនិយោគិនបរទេសមកពីគ្រប់ប្រទេសដើម្បីចូលមកបណ្តាក់ទុនក្នុងប្រទេសកម្ពុជាជាអតិបរមាដែលជាការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ខណៈដែលកម្ពុជាមានទីតាំងជាចំណុចកណ្តាលនៃតំបន់អាស៊ីអាគ្នេយ៍ និងជាច្រកទីផ្សារដ៏ធំទូលាយរួមជាមួយកត្តាសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាព លំនឹងម៉ាក្រូសេដ្ឋកិច្ច ធនធានមនុស្ស កម្លាំងពលកម្មវ័យក្មេង និងសកម្មជាច្រើន និងការអភិវឌ្ឍឥតឈប់ឈរលើហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទ ដែលផ្តល់ភាពងាយស្រួលសម្រាប់ផលិតកម្ម និងការដឹកជញ្ជូនជាពិសេសការគាំទ្រ ការលើកទឹកចិត្ត ពីសំណាក់រាជរដ្ឋាភិបាល ដែលធ្វើឱ្យកម្ពុជាក្លាយជាទីតាំងដ៏មានសក្តានុពលខ្លាំងក្លាសម្រាប់ការវិនិយោគគ្រប់ប្រភេទប្រកបដោយជំនឿទុកចិត្តខ្ពស់ ។









# អ្នកឧកញ៉ា ហ៊ុន ឡាក់ ចូលរួម «កិច្ចប្រជុំស្តីពីការរៀបចំកម្មវិធីគាំទ្រថ្មី ក្នុងការពង្រឹងនិងពង្រីកបណ្តុំឧស្សាហកម្មនិងជំរុញការផ្សារភ្ជាប់ខ្សែច្រវាក់ផលិតកម្មរវាង សហគ្រាសធុនតូច និងមធ្យម និងវិនិយោគិនធំៗក្នុងស្រុក និងបរទេស»










នាថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ អ្នកឧកញ៉ា ហ៊ុន ឡាក់ អគ្គលេខាធិការនៃសមាគមឧកញ៉ាកម្ពុជា និងសហការី បានចូលរួម «កិច្ចប្រជុំស្តីពីការរៀបចំកម្មវិធីគាំទ្រថ្មីក្នុងការពង្រឹង និងពង្រីកបណ្តុំឧស្សាហកម្ម និងជំរុញការផ្សារភ្ជាប់ខ្សែច្រវាក់ផលិតកម្មរវាងសហគ្រាសធុនតូច និងមធ្យម និងវិនិយោគិនធំៗក្នុងស្រុក និងបរទេស» ដែលបានប្រព្រឹត្តិទៅនៅទីស្នាក់ការមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) ក្រោមកិច្ចដឹកនាំដោយ លោក គី សុខគីម នាយកប្រតិបត្តិ SDF ដោយមានការចូលរួមពីតំណាងសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា (CPMEC), ម្ចាស់សហគ្រាសធុនតូច និងមធ្យម ដែលមានសក្តានុពល, វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) និងឧទ្យាននវានុវត្តន៍សង្គមអង្គរ (ASIP)។

កិច្ចប្រជុំនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិភាក្សា និងស្វែងយល់ពីបញ្ហាប្រឈម និងតម្រូវការរបស់ម្ចាស់សហគ្រាសធុនតូច និងមធ្យម (SMEs) និងវិនិយោគិនធំៗក្នុងស្រុក និងបរទេស ដើម្បីជាធាតុចូលសម្រាប់រៀបចំកម្មវិធីគាំទ្រថ្មី សំដៅដោះស្រាយបញ្ហាជាប្រព័ន្ធក្នុងខ្សែច្រវាក់ផលិតកម្ម និងការអភិវឌ្ឍមូលធនមនុស្សផ្សារភ្ជាប់ទៅនឹងតម្រូវការវិនិយោគិន។ ក្នុងឱកាសនៃកិច្ចប្រជុំនេះ ក្រុមការងាររបស់ SDF បានចែករំលែកពីកម្មវិធីគាំទ្រថ្មីមួយ ដែល SDF បានសំយោគបទពិសោធពីប្រទេសសិង្ហបុរី (Queen Bee Program) ក្នុងគោលបំណងពង្រឹង និង ពង្រីកបណ្តុំឧស្សាហកម្ម និងជំរុញការផ្សារភ្ជាប់ខ្សែច្រវាក់ផលិតកម្មរវាងសហគ្រាសធុនតូច និងមធ្យម និងវិនិយោគិនធំៗក្នុងស្រុក និងបរទេស សំដៅលើកកម្ពស់សមត្ថភាព, ភាពប្រកួតប្រជែង និងភាពរីកចម្រើនទាំងវិស័យ SMEs និងឧស្សាហកម្មធំៗក្នុងស្រុក ឆ្ពោះទៅរកការផ្គត់ផ្គង់សម្រាប់តម្រូវការទីផ្សារក្នុងស្រុក និងការនាំចេញទៅថ្នាក់តំបន់ និងអន្តរជាតិ។

ជាមួយគ្នានេះ អ្នកឧកញ៉ា ហ៊ុន ឡាក់ បានសម្តែងការគាំទ្រ និងមានសុទិដ្ឋិនិយមខ្ពស់ចំពោះការរៀបចំកម្មវិធីគាំទ្រធុរកិច្ចនេះ ដែលនឹងជួយដល់សហគ្រាសគ្រប់កម្រិតក្នុងការផ្តល់ការគាំទ្រ និងផ្តល់អត្ថប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ដើម្បីបង្កើនសមត្ថភាពផលិតកម្ម ភាពប្រកួតប្រជែង និងប្រតិបត្តិការធុរកិច្ចរបស់ខ្លួនឱ្យកាន់តែមានភាពរីកចម្រើនរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ បន្ថែមលើនេះ អ្នកឧកញ៉ាបានចែក រំលែកបទពិសោធន៍ និងបញ្ហាប្រឈមនានា ក្នុងការធ្វើធុរកិច្ច ជាពិសេសក្នុងវិស័យកសិកម្ម កសិឧស្សាហកម្ម និងការកែច្នៃអាហារដែលបញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវដោះស្រាយដើម្បីជំរុញឱ្យវិស័យកសិកម្មកម្ពុជាកាន់តែមានសក្តានុពល និងមានការអភិវឌ្ឍ។ អ្នកឧកញ៉ាបានលើកឡើងបន្ថែមថា សមាគមឧកញ៉ាកម្ពុជា ជាបណ្តុំធុរជន និងវិនិយោគិនមកពីចម្រុះវិស័យ ដែលតែងតែងផ្តល់ការគាំទ្រ និងកិច្ចសហការលើគ្រប់សកម្មភាពពាណិជ្ជកម្ម និងអាជីវកម្ម ដូច្នេះ សមាគមនឹងពាំនាំនូវកម្មវិធីគាំទ្ររបស់ SDF តាមរយៈការរៀបចំជាសិក្ខាសាលាផ្សព្វផ្សាយដល់សមាជិកនាពេលខាងមុខដើម្បីជាអត្ថប្រយោជន៍សម្រាប់សមាជិកក្នុងការរៀបចំផែនការ និងកម្មវិធីអភិវឌ្ឍន៍អាជីវកម្មរបស់ខ្លួនឱ្យកាន់តែមាន ប្រសិទ្ធភាព ភាពរីកចម្រើន និងជោគជ័យបន្ថែមទៀត។

ជាលទ្ធផលនៃកិច្ចពិភាក្សា អង្គប្រជុំបានឯកភាពលើជំហានបន្ទាប់ដើម្បីធ្វើការរួមគ្នាដូចខាងក្រោម៖

១. សម្រាប់ឆ្នាំនេះ SDF នឹងធ្វើការងារបន្តជាមួយភាគីពាក់ព័ន្ធទាំងវិស័យឯកជន និងស្ថាប័នស្រាវជ្រាវ ដើម្បីធ្វើឱ្យកម្មវិធីនេះអាចអនុវត្តបានហើយ SDF នឹងរៀបចំឯកសារពាក់ព័ន្ធ គោលការណ៍ និងលក្ខខណ្ឌតម្រូវនានាដើម្បីពិភាក្សា និងដាក់ឱ្យធ្វើតេស្តសាកល្បងជាមួយដៃគូនាចុងឆ្នាំ។

២. សមាគមឧកញ៉ាកម្ពុជា, CPMEC និងភាគីពាក់ព័ន្ធចាប់ដៃគ្នា រៀបចំសិក្ខាសាលា និងកិច្ចប្រជុំពិភាក្សា និងផ្សព្វផ្សាយពីកម្មវិធីគាំទ្ររបស់ SDF ទៅកាន់សមាជិករបស់ខ្លួន ដើម្បីរៀបចំផែនការ និងកម្មវិធីអភិវឌ្ឍន៍អាជីវកម្មដោយផ្សារភ្ជាប់នឹងការអភិវឌ្ឍធនធានមនុស្ស។

៣. SDF នឹងសហការជាមួយស្ថាប័នស្រាវជ្រាវក្នុងស្រុក និងក្នុងតំបន់ដើម្បីពង្រឹង និងពង្រីកសមត្ថភាពធនធានមនុស្ស លើផ្នែកស្រាវជ្រាវនិងអភិវឌ្ឍន៍បែបអនុវត្ត (Applied Research & Development) ដើម្បីផ្តល់ដំណោះស្រាយ អាជីវកម្មជាក់ស្តែង លើវិស័យកែច្នៃកសិផល, កសិកម្មទំនើប និងផលិតកម្មជាដើម។









## ទំនាក់ទំនងនិងទទួលបានព័ត៌មានអំពីយើងខ្ញុំតាមរយៈ

| Telegram | Facebook | TikTok | Website | Youtube | X(Twitter) |
| --- | --- | --- | --- | --- | --- |


ទីស្នាក់ការ សណ្ឋាគារភ្នំពេញ លេខ៥៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

(+៨៥៥) ២៣ ៨៦០ ៩៩៩ info@cambodianoknha.org www.cambodianoknha.org